CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៣០ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ Cathy De Leon, ប្រធានសាខាផ្នែកសេវាកម្មបណ្ណាល័យ, បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច, 562.570.6420

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចផ្តល់ជូនការចូលប្រើដោយគ្មានដែនកំណត់នូវសៀវភៅស្តាប់និងសៀវភៅអេឡិចត្រូនិចមួយចំនួនស្តីអំពីការប្រឆាំងនឹងការប្រកាន់បុចសាសន៍និងចលនាជីវិតជនស្បែកខ្មៅក៏សំខាន់

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - តាមរយៈភាពជាដៃគូជាមួយ Overdrive បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច (LBPL) និងឈ្មួញលក់សៀវភៅស្តាប់និងសៀវភៅអេឡិចត្រូនិចដ៏បណ្ណាល័យនឹងផ្តល់ជូនការចូលប្រើប្រាស់ដោយគ្មានដែនកំណត់នូវសៀវភៅអេឡិចត្រូនិចនិងសៀវភៅស្តាប់ស្តីអំពីការប្រឆាំងនឹងការប្រកាន់បុចសាសន៍និងយុត្តិធម៌សង្គមសម្រាប់អ្នកកាន់ប័ណ្ណបណ្ណាល័យសាធារណៈនៃឡុងប៊ិច។ សៀវភៅអេឡិចត្រូនិចអាចប្រើបានសម្រាប់ការអាននៅលើឧបករណ៍ចល័តដូចជាស្មាតហ្វូនថេប្លេតឬកុំព្យូទ័រ។

យោងតាមការសន្ទនាក្នុងស្រុកនិងថ្នាក់ជាតិនាពេលបច្ចុប្បន្នអំពីវិសមភាពសង្គមនិងចលនាជីវិតជនស្បែកខ្មៅក៏សំខាន់តម្រូវការសៀវភៅបែបនេះបានកើនឡើងហើយហាងលក់សៀវភៅនិងបណ្ណាល័យជាច្រើនបានអស់សៀវភៅនិងច្បាប់ចម្លងសៀវភៅអេឡិចត្រូនិចដែលមានអាជ្ញាប័ណ្ណដែលស្តីអំពីការប្រឆាំងនឹងការប្រកាន់បុចសាសន៍និងចំណងជើងផ្តោតលើចលនាជីវិតជនស្បែកខ្មៅក៏សំខាន់។

លោកស្រី Glenda Williams នាយកបណ្ណាល័យបានមានប្រសាសន៍ថា "បណ្ណាល័យសាធារណៈមានសក្តានុពលដើរតួនាទីយ៉ាងសំខាន់ក្នុងការលុបបំបាត់ការរើសអើងជាតិសាសន៍នៅក្នុងប្រទេសរបស់យើង។ តាមរយៈការធ្វើឱ្យធនធានសិក្សាទាំងនេះមានសម្រាប់ប្រជាជនរបស់យើងយើងអាចជួយសហគមន៍របស់យើងឱ្យយល់កាន់តែច្បាស់ពីបទពិសោធន៍របស់សហគមន៍ជនជាតិស្បែកខ្មៅហើយរួមគ្នាអភិវឌ្ឍភាសារួមដែលគាំទ្រដល់ជីវិតជនជាតិស្បែកខ្មៅនិងសកម្មភាពប្រឆាំងនឹងការរើសអើងជាតិសាសន៍។"

សៀវភៅដែលមានចំណងជើងខាងក្រោមគឺមានឥឡូវនេះដោយគ្មានដែនកំណត់៖

- *The New Jim Crow: Mass Incarceration in the Age of Colorblindness*, by Michelle Alexander (សៀវភៅស្តាប់)
- *The Hate U Give* by Angie Thomas (សៀវភៅអេឡិចត្រូនិចនិងសៀវភៅស្តាប់)
- *Me and White Supremacy: Combat Racism, Change the World, and Become a Good Ancestor* by Layla F. Saad (សៀវភៅអេឡិចត្រូនិចនិង)

សៀវភៅទាំងនេះគឺផ្តល់ជូនតាមរយៈកម្មវិធីរបស់Overdrive គឺជីវិតជនស្បែកខ្មៅក៏សំខាន់៖ការអានជាសហគមន៍។ សៀវភៅជាច្រើននឹងត្រូវបន្ថែមនៅក្នុងសប្តាហ៍ខាងមុខនេះ។ អ្នកកាន់ប័ណ្ណបណ្ណាល័យអាចចូលអានសៀវភៅទាំងនេះបានដោយចូលទៅកាន់គេហទំព័រ Overdrive របស់បណ្ណាល័យសាធារណៈនៅទីនេះ។ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបទទួលបានប័ណ្ណបណ្ណាល័យសូមចូលទៅកាន់គេហទំព័រ៖ http://www.longbeach.gov/library/borrow/get-a-library-card/។

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះអតិថិជនអាចទាក់ទងមកបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចតាមរយៈលេខ 562.570.7500 ចន្លោះម៉ោង ១០ ព្រឹកទៅម៉ោង ៥ ល្ងាចពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀន

ដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

## អំពីបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច

បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1896 ដែលបម្រើដល់ទីក្រុងចម្រុះដែលមានប្រជាជនជិតកន្លះលាននាក់។ ប្រព័ន្ធបណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចរួមមានបណ្ណាល័យ Billie Jean King Main Library និងបណ្ណាល័យសង្កាត់ចំនួន 11 និងវត្តមាននៅលើអ៊ីនធឺណិតយ៉ាងរស់រវើក។ នៅរដូវក្តៅឆ្នាំ 2017 បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់មេដាយថ្នាក់ជាតិសម្រាប់បណ្ណាល័យនិងសារមន្ទីរក្នុងការទទួលស្គាល់ការសហការសហគមន៍ដែលមានការជោគជ័យ ព្រមទាំងកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ប្រកបដោយភាពច្នៃប្រឌិតក៏ដូចជាការផ្តល់កម្មវិធីផ្តោតលើអក្ខរកម្មដល់ប្រជាជននៅទីក្រុងឡុងប៊ិច។ ដោយផ្តោតលើការផ្តល់ព័ត៌មានដោយឥតគិតថ្លៃនិងស្មើភាពគ្នានិងការគាំទ្រការរៀនសូត្រពេញមួយជីវិតបណ្ណាល័យផ្តល់ជូននូវសៀវភៅ ប្រព័ន្ធផ្សព្វផ្សាយ មូលដ្ឋានទិន្នន័យ អ៊ិនធឺណែត មជ្ឈមណ្ឌលសិក្សាជាលក្ខណៈគ្រួសារ កន្លែងផលិតនិងព្រឹត្តិការណ៍ជាច្រើនទៀតរាប់ចាប់ពីការនិទានរឿងរហូតដល់កម្មវិធីវប្បធម៌។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ www.lbpl.org។ សូមមេត្តាចូលចិត្ត (Like) បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គម Facebook និងតាមដានយើងខ្ញុំតាមបណ្តាញសង្គម Twitter និង Instagram។

\# # #